ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

----

ខ្ញុំបាទ-នាងខ្ញុំ ជាប្រជាជនរងផលប៉ះពាល់ ដោយគំរោងសាងសង់ផ្លូវជាតិលេខ១ (អ្នកលឿង-បាវិត) ចំនួន២២គ្រួសារ ដែលកំពុងរស់នៅក្នុងសហគមន៍ស្ទឹងស្លូត ឃុំអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង។

យើងខ្ញុំជាអ្នកប៉ះពាល់ ដោយគំរោងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អនុតំបន់ទន្លេរមេគង្គ (GMS) ហាយវ៉េភ្នំពេញ-ហូជីមិញ គំរោងកម្ចីលេខ (1659-CAM)ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។តាមរយៈគំរោងជំនួយបច្ចេកទេសសំរាប់ការកសាងសមត្ថភាព អំពីការគ្រប់គ្រងហានីភ័យគំរោងតាំងទីលំនៅថ្មី របស់ធនាគារអភិវឌ្ឍន៍អាស៊ី (TA6091-REG)បានធ្វើការសវនកម្មលើគំរោងនេះ។ តែជំនួយបច្ចេកទេសនេះមិនបានដោះស្រាយបញ្ហារបស់យើងខ្ញុំទេ។

<u>សូមគោរពចូលមក</u>


លោកប្រធានគំរោងសម្របសម្រួលគំរោងពិសេស (SPF)

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

6 ADB Avenue, Mandaluyong City 0401<br>
Phillippines<br>
Fax: +632-636-2490<br>
Email: spf@adb.org


<u>កម្មវត្ថុៈ</u> សំណើសុំលោកប្រធានសម្របសម្រួលគំរោងពិសេស មេត្តាជួយផ្តល់ថវិកាបន្ថែម ដល់យើងខ្ញុំ ដែលកំពុងខ្វះខាតជីវភាព បាត់បង់មុខរបរចិញ្ចឹមជីវិត ថែមទាំងជំពាក់បំណុលយ៉ាងច្រើន ចាប់តាំងពីផ្ទះយើងខ្ញុំត្រូវបានរុះរើមកម្ល៉េះ។ យើងខ្ញុំសូមលើកសំណូមពរដូចខាងក្រោមនេះ

- យើងខ្ញុំសូមលោកប្រធានមេត្តាជួយស្នើសុំប្លង់កម្មសិទ្ធិដីធ្លី ដល់យើងខ្ញុំ ដែលបានរស់នៅលើទីតាំងថ្មីបច្ចុប្បន្ននេះ ចំនួន៥ឆ្នាំមកហើយ។
- យើងខ្ញុំស្នើសុំឱ្យមានគំរោងបង្កើតមុខរបរ និងផ្តល់ថវិកាសំរាប់ជាទុនក្នុងការប្រកបមុខរបរដោះស្រាយជីវភាព លុបបំបាត់ភាពក្រីក្ររបស់យើងខ្ញុំ។

- យើងខ្ញុំស្នើសុំឱ្យលោកប្រធាន មេត្តាអង្កេត មិនត្រឹមតែករណីរបស់យើងខ្ញុំទេ តែសូមឱ្យមានការអង្កេត-ដោះស្រាយ ដល់ប្រជាជនប៉ះពាល់ផ្សេងទៀត រាប់បញ្ចូលទាំងប្រជាជនប៉ះពាល់ ដែលមិនទាន់បានទទួលសំណងពេញលេញផងដែរ។
- យើងខ្ញុំសូមឱ្យលោកប្រធាន រៀបចំដំណើរការគំរោងអភិវឌ្ឍន៍ ជៀសវាងនូវការប៉ះពាល់ដល់ប្រជាជនផ្សេងទៀត។

យើងខ្ញុំនឹងដាក់ជូននូវឯកសារផ្សេងៗទៀត បន្ថែមលើពាក្យបណ្តឹងសារទុក្ខនេះ ថែមទៀត។

សូមលោកប្រធានមេត្តាឆ្លើយតបមកយើងខ្ញុំ ទាំងជាភាសាខ្មែរ និងភាសាអង់គ្លេស។

យើងខ្ញុំសូមប្រគល់សិទ្ធិសំរាប់ទំនាក់ទំនង ជូនដល់ លោក សូត្រ សុផុន ប្រធានស្តីទី អង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា CDCam ដែលមានអាស័យដ្ឋាន:
ផ្ទះលេខ 42AE0ផ្លូវលេខ 488 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទលេខ (៨៥៥ )១២ ៩៣២ ៨០៤ រឺ ១១ ៦៦ ៤៨ ៩៣
អ៊ីម៉ែល cdcam@mail.com or info@cdcam.org

សូមលោកប្រធានមេត្តាទទួលយកនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅថ្ងៃ25ខែកក្កដា ឆ្នាំ២០០៧
ប្រធានសហគមន៍ស្ទឹងស្លុត

ភិន វណ្ណា

## តារាងរាយនាមប្រជាជនប៉ះពាល់គំរោងហាវ៉េយ១

## សមាជិកសហគមន៍ស្ទឹងស្វូត ក្នុងទីតំបន់តាំងទីលំនៅថ្មី

## ឃុំអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង

| ល.រ | នាម_គោត្តនាម | ភេទ | អាយុ | ចំនួនសមាជិកក្នុងគ្រួសារ | | ឆ្នាំក្នុងតំបន់តាំងទីលំនៅថ្មី | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ប្រុស | ស្រី | | |
| ១ | ហិន វណ្ណា | ស | 52 | 2 | 2 | ឆ្នាំ២០០០ - 5 | |
| ២ | ជិន សម្បត្តិ | ប | 52 | 2 | 2 | 〃 - 1 | |
| ៣ | ហម់ ស៊ីប | ស | 48 | 2 | 4 | 〃 - 17 | |
| ៤ | គម់ ផល្លី | ស | 38 | 1 | 3 | 〃 - 16 | |
| ៥ | គិប រ៉ី | ប | 55 | 2 | 4 | 〃 - 15 | |
| ៦ | ចឿម សុខ | ប | 36 | 2 | 3 | 〃 - 10 | |
| ៧ | ម៉ុយ សាម៉ឿន | ប | 45 | 3 | 1 | 〃 - 14 | |
| ៨ | ស៊ៅ សាអ៊ាយ | ប | 48 | 3 | 1 | 〃 - [illegible] | |
| ៩ | ចើ ហ៊ន | ប | 55 | 4 | 2 | 〃 - 6 | |
| ១០ | ចឿន សារិន | ប | 35 | 5 | 3 | 〃 - 8 | |
| ១១ | គ្រើ ចឿន | ស | 60 | 2 | 2 | 〃 - 7 | |
| ១២ | ញៀម ជីយាម | ស | 56 | 1 | 2 | 〃 - 9 | |
| ១៣ | ស៊ូ យស៊ីមឿន | ប | 48 | 5 | 3 | 〃 - 13 | |
| ១៤ | ញៀម យស៊ីម | ប | 36 | 3 | 2 | 〃 - 11 | |
| ១៥ | ញៀម យុម យ៉ាម | ប | 42 | 3 | 2 | 〃 - 2 | |
| ១៦ | ចេហ ប៉ាម | ស | 41 | 1 | 3 | 〃 - 3 | ស៊ុន ចាន់លក (ស្លាប់) |
| ១៧ | ក្លាយ យ៉ែន | ប | 35 | 3 | 1 | - 〃 - | |
| ១៨ | ប៉ាយ សាឡឿន | ស | 30 | 2 | 1 | - 〃 - | |
| ១៩ | ប៉ាយ ស ហ៊ី | ស | 45 | 3 | 2 | - 〃 - | |
| ២០ | ខាត់ សាម៉ុន | ស | 35 | 1 | 3 | - 〃 - | ខាត់ ចឿន (ស្លាប់) |
| ២១ | ប៉ាយ ម៉ឺន | ប | 43 | 2 | 3 | - 〃 - | |
| ២២ | វ៉ា ចំ ទូ | ស | 67 | 1 | 3 | - 〃 - | |